**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៣៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ឬចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩១៣ /៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣ /១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រែប្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ៤១៧ សជណ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៩៦៣ សជណ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤០២ សជណ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៩០០ សជណ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៨៥០ លស ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ

www.pheakdeylaw.com

**សម្រេច**

**មាត្រា ១ :-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដូចខាងក្រោម÷

- ដីទំនេររបស់មន្ទីររ៉ែ និងថាមពល ខេត្តពោធិ៍សាត់ ស្ថិតនៅភូមិស្ថានីយ៍ សង្កាត់ស្វាយអាត់ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានទំហំដី ១.២៤៤ ម៉ែត្រក្រឡា។
- ដីទំនេរចំនួន ០២កន្លែងរបស់សាលាស្រុកអង្គរជ័យ ខេត្តកំពត ទីតាំងទីមួយដីទំហំ ២.១៦៣ ម៉ែត្រក្រឡា ស្ថិតនៅតាមបណ្តោយ ផ្លូវជាតិលេខ ៣១ ភូមិពោធិ៍ ឃុំភ្នំកុង ខេត្តកំពត ទីតាំងដីមានទំហំ ១.០៥០ ម៉ែត្រក្រឡា ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ១២៦ ភូមិប្រាល ឃុំតានី ស្រុកអង្គជ័យ ខេត្តកំពត និងដីនៅសល់ផ្នែកខាងក្រោយទំហំ ១.០៧៣ ម៉ែត្រក្រឡា។
- ពន្ធនាគារខេត្តពោធិ៍សាត់ របស់ក្រសួងមហាផ្ទៃ ស្ថិតនៅភូមិចំការចេកខាងជើង ឃុំផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានទំហំដី ១០.០៣៩ ម៉ែត្រក្រឡា។
- អតីតផ្ទះសំណាក់ព្រាបស របស់ក្រសួងពាណិជ្ជកម្ម ស្ថិតនៅដីឡូតិ៍លេខ៧៧ ផ្លូវលេខ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានទំហំដី ៥១៨,៦៨ ម៉ែត្រក្រឡា។

**មាត្រា ២ :-**

- ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធី ដោយក្រសួងមហាផ្ទៃ ក្រសួងរ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម។

**មាត្រា ៣ :-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com